ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំ
អង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករ
សេដ្ឋកិច្ចក្រៅប្រព័ន្ធ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន អំពីលទ្ធផលការចាក់វ៉ាក់សាំងស៊ីណូវ៉ាក់ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ដោយថ្ងៃនេះ អនុគណៈកម្មការចំពោះកិច្ចបានបើកទីតាំងចាក់វ៉ាក់សាំងចំនួន ៤ទីតាំងបន្ថែម សរុបទាំងអស់ចំនួន ១៨ទីតាំង ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**ក-លទ្ធផលក្នុងថ្ងៃទី១៤ ខែមេសា**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ១៥ ៧៧៥នាក់ (បរទេសចំនួន ៧០៨នាក់)
- ចាក់បានចំនួន ១៥ ២៩៣នាក់ (បរទេសចំនួន ៧០៨នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៤៨២នាក់ (បរទេសចំនួន ០នាក់)។

**ខ-លទ្ធផលគិតត្រឹមថ្ងៃនេះ**

- អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ៨៣ ៨៩៤នាក់ (បរទេសចំនួន ៣ ៣៣៦នាក់)
- ចាក់បានចំនួន ៨១ ១១៦នាក់ (បរទេសចំនួន ៣ ៣១៦នាក់)
- គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ២ ៧៧៨នាក់ (បរទេសចំនួន ២០នាក់)។

អនុគណៈកម្មការចំពោះកិច្ច នឹងបន្តរៀបចំទីតាំងចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ជាបន្តបន្ទាប់ទៀត។

អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១